<u>សិក្ខាសាលាជាតិស្តីពីការរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០១៧</u>

<u>នៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ</u>

<u>ថ្ងៃទី២៤-២៥ ខែវិច្ឆិកា ឆ្នាំ២០១៦ នៅក្រសួងមហាផ្ទៃ</u>

សុន្ទរកថារបស់លោក **សឿង សារឿន** នាយកអង្គការ

គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) និងតំណាងអង្គការសង្គមស៊ីវិល

---

**សូមគោរព!** ឯកឧត្តមបណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សូមគោរព!** ឯកឧត្តមរដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ក្រុមប្រឹក្សា អភិបាល និងតំណាងក្រសួងស្ថាប័នរបស់រដ្ឋាភិបាល ខេត្ត ស្រុក និងក្រុង តំណាងអង្គការសង្គមស៊ីវិល និងសហសេរិកដៃគូអភិវឌ្ឍន៍ទាំងអស់។

**សូមគោរពភ្ញៀវកិត្តិយស អស់លោក លោកស្រី**

ក្នុងនាមគណៈកម្មការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) ក្រុមការងារវិមជ្ឈការតាមរយៈភាពជាដៃគូ (WGPD) អង្គការសង្គមស៊ីវិលដែលធ្វើការងារលើការអនុវត្តក្របខ័ណ្ឌគណនេយ្យភាពសង្គម និងសិក្ខាកាមជាសង្គមស៊ីវិលនានា ខ្ញុំសូមសម្តែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាលកម្ពុជា ជាពិសេសក្រសួងមហាផ្ទៃ និង គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (NCDD) ដែលបានអនុញ្ញាតិឲ្យខ្ញុំបាទ និងសហសេរិកពីសង្គមស៊ីវិលបានចូលរួមក្នុង**សិក្ខាសាលាជាតិស្តីពីការរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០១៧ នៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ** នាថ្ងៃនេះ។ ខ្ញុំសូមថ្លែងអំណរគុណជាអណែកចំពោះមិត្តភក្តិពីអង្គការសង្គមស៊ីវិលដែលទុកចិត្តខ្ញុំឲ្យឡើងថ្លែងសុន្ទរកថាជំនួសនៅពេលនេះ។ ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរចំពោះដៃគូអភិវឌ្ឍន៍ទាំងឡាយ ជាពិសេសសហគមន៍អឺរ៉ុប និងរដ្ឋជាសមាជិកមួយចំនួន ធនាគារពិភពលោក និងធនាគារអេឌីប៊ី ដែលចូលរួមផ្តល់ការគាំទ្រទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុដល់ទាំងរាជរដ្ឋាភិបាល និងសង្គមស៊ីវិលសំរាប់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ (D&D) ជិត១០ឆ្នាំកន្លងមកនេះ។

សង្គមស៊ីវិលសូមវាយតម្លៃខ្ពស់ចំពោះសមិទ្ធិផលសំខាន់ៗ និងវឌ្ឍនភាពជាច្រើនពាក់ព័ន្ធនឹងការអភិវឌ្ឍន៍តាមបែបប្រជាធិតេយ្យនៅថ្នាក់ក្រោមជាតិ ក្នុងឆ្នាំ២០១៦ ដូចជាៈ ១) **ការលើកកំពស់គណនេយ្យភាពសង្គម**តាមរយៈការអនុវត្តន៍ក្របខណ្ឌជាយុទ្ធសាស្រ្តគណនេយ្យភាពសង្គម ២) **ការផ្ទេរមុខងារ**មួយចំនួនពាក់ព័ន្ធវិស័យអប់រំ សុខាភិបាល និងអភិវឌ្ឍន៍ជនបទ ៣) **ការអភិវឌ្ឍន៍ធនធានមនុស្ស** ៤) **ការលើកកំពស់ការផ្តល់សេវា**ប្រកបដោយគុណ

ភាព និងផ្តួចផ្តើម ឲ្យមាន**ភាពជាដៃគូប្រកបដោយបរិយាប័ន និងពហុភាគី** និង ៥) ការជំរុញ**ប្រសិទ្ធភាព និងនិរន្តរភាពហិរញ្ញវត្ថុ** តាមរយៈការគ្រប់គ្រង**ហិរញ្ញប្បទាន និងមូលនិធិក្រុង/ស្រុក**។

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីជាទីគោរព!**

សង្គមស៊ីវិលយល់ឃើញថា កំណែទម្រង់វិមជ្ឈការគឺជាការលើកកម្ពស់ការអភិវឌ្ឍប្រជាធិបតេយ្យនៅមូលដ្ឋាន និងជាការឆ្លើយតបប្រកបដោយតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាពទៅនឹងតម្រូវការរបស់ប្រជាជន។ វាទាមទារឲ្យមានវិធីសាស្ត្រពហុភាគី និងបរិយាកាសដ៏ល្អមួយដែលអាចឲ្យតួអង្គអភិវឌ្ឍ/ភាគីពាក់ព័ន្ធទាំងអស់ (រដ្ឋ និង មិនមែនរដ្ឋ) រួមទាំងប្រជាពលរដ្ឋ ស្ត្រី និងយុវជន ដើរតួនាទីចំបងរបស់ខ្លួនក្នុងដំណើរការកំណែទម្រង់នេះ។

ខ្ញុំសូមអនុញ្ញាតដាក់ជូនអង្គសិក្ខាសាលានូវយោបល់គន្លឹះមួយចំនួនដែលអង្គការសង្គមស៊ីវិលមាន ទៅលើផែនការ និងថវិកាប្រចាំឆ្នាំ២០១៧ ដូចខាងក្រោម៖

1. **ជំរុញភាពជាដៃគូរវាងផ្នែកតម្រូវការ-អ្នកផ្គត់ផ្គង់ និងកិច្ចសហប្រតិបត្តិការ៖** យើងបានសិក្សារៀនសូត្រនូវការអនុវត្តល្អមួយចំនួនទាក់ទងនឹងកិច្ចសហប្រតិបត្តិការរវាងរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលក្នុងការអនុវត្តក្របខ័ណ្ឌគណនេយ្យភាពសង្គម (ISAF)។ ជាមួយគ្នានិងស្រដៀងគ្នានេះ អង្គការសង្គមស៊ីវិលអំពាវនាវ និងលើកទឹកចិត្តដល់រដ្ឋាភិបាល ១) **ដាក់បញ្ចូលអង្គការសង្គមស៊ីវិលជាសមាជិក អនុក្រុមការងារ**ផ្សេងទៀត ដូចជាការផ្ទេរមុខងារ ធនធានមនុស្ស និងការអភិវឌ្ឍសមត្ថភាព និងការគ្រប់គ្រងសារពើពន្ធ។ ២) **គំរូនៃភាពភាពជាដៃគូរវាងផ្នែកតម្រូវការ និងផ្គត់ផ្គត់នេះ ក៏គួរត្រូវបានបង្កើតឡើងផងដែរនៅថ្នាក់ក្រោមជាតិ** ដោយសារវាមិនត្រឹមតែជួយលើកកម្ពស់ការទំនាក់ទំនង និងទំនុកចិត្តក្នុងចំណោមផ្នែកតម្រូវការ និងផ្គត់ផ្គត់ ព្រមទាំងការលើកកំពស់ការចូលរួមយ៉ាងសកម្មពីសំណាក់ប្រជាពលរដ្ឋ ជាពិសេសស្ត្រី និងយុវជនប៉ុណ្ណោះទេ ប៉ុន្តែ វាថែមទាំងមានប្រសិទ្ធភាពផងដែរទាក់ទងនឹងការដោះស្រាយបញ្ហាប្រឈមនៅថ្នាក់មូលដ្ឋាន និង ៣) **បង្កើនបរិយាកាសអំណោយផលដល់អង្គការសង្គមស៊ីវិល**ដូចជាៈ ក) ការកែសំរួលមាត្រាមួយចំនួន នៅក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីសមគម និងអង្គការមិនមែនរដ្ឋាភិបាលដែលមានភាពស្មុគ្រស្មាញក្នុងការអនុវត្តជាក់ស្តែង ខ)ការរៀបចំជាប្រចាំនូវ**សិក្ខាសាលាថ្នាក់ជាតិ/ក្រោមជាតិស្តីពី "ការលើកកម្ពស់ភាពជាដៃគូប្រកបដោយប្រសិទ្ធភាពរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសង្គមស៊ីវិល"** សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពក្នុងប្រទេសកម្ពុជា។ យើងសង្ឃឹមថា ក្រសួងមហាផ្ទៃអាចដើរតួនាទីនាំមុខមួយក្នុងបញ្ហានេះ។

2. **យុទ្ធសាស្ត្រប្រាស្រ័យទាក់ទង៖** អង្គការសង្គមស៊ីវិលមានឆន្ទៈធ្វើការងារក្នុងភាពជាដៃគូជាមួយ NCDD-S សម្រាប់ការអនុវត្តយុទ្ធសាស្ត្រប្រាស្រ័យទាក់ទង ដើម្បីធានាឲ្យបាននូវការយល់ដឹងរបស់ប្រជាពលរដ្ឋ និងលទ្ធភាពទទួលបានទិន្នន័យដោយចំហរសម្រាប់ការលើកកម្ពស់តម្លាភាពសារពើពន្ធ។ វាក៏នឹងកាន់តែមានប្រសិទ្ធភាពជាងនេះផងដែរ ប្រសិនបើរដ្ឋាភិបាលពន្លឿនការបង្កើតច្បាប់/បទប្បញ្ញត្តិស្តីពីសិទ្ធិទទួលបានព័ត៌មាននោះ។

3. **<u>ការអភិវឌ្ឍសមត្ថភាព៖</u>** ដោយសារទំហំវិនិយោគដែលបានធ្វើឡើង អង្គការសង្គមស៊ីវិលនៅតែមានក្តីបារម្ភ ទាក់ទងនឹងនិរន្តរភាព (តម្លៃធៀបនិងថវិកា) នៃការវិនិយោគលើការអភិវឌ្ឍសមត្ថភាព និងថាតើវាកំពុងបង្កើត និងគាំទ្រដល់ការផ្លាស់ប្តូរគ្រប់គ្រាន់ទាក់ទងនឹងចំណេះដឹង ឥរិយាបថ និងជំនាញរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រុមប្រឹក្សាឬយ៉ាងណា។ នៅទីណាដែលអាចធ្វើបាន អង្គការសង្គមស៊ិវិលនឹងគាំទ្រដល់ការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការចែករំលែកការអនុវត្តល្អ និងមេរៀនជាបទពិសោធ តាមរយៈការផ្តល់ការបណ្តុះបណ្តាលបំពេញបន្ថែម ការណែនាំ ការបង្ហាត់បង្រៀនក្នុងវិស័យនានាៗដូចជា រដ្ឋបាល គណនេយ្យភាព ការចូលរួមរបស់ប្រជាពលរដ្ឋ ការប្រឹក្សាឧបករណ៍គណនេយ្យភាពសង្គម សមភាពយេនឌ័រ និងបញ្ហានានាដែលពាក់ព័ន្ធនឹងលទ្ធភាពទទួលបានព័ត៌មាន។

4. **<u>គុណភាពនៃការផ្តល់សេវា៖</u>** អង្គការសង្គមស៊ីវិលបានទទួលស្គាល់នូវវឌ្ឍនភាពដែលបានធ្វើឡើងនៅថ្នាក់ជាតិពាក់ព័ន្ធនឹងការបង្កើតអនុក្រឹត្យ គោលនយោបាយ និងឯកសារគាំទ្រផ្សេងៗទៀត។ ទោះជាយ៉ាងណា ការកែលម្អពិតប្រាកដនៃគុណភាពសេវាសាធារណៈដល់ប្រជាពលរដ្ឋមិនសូវបានផ្តោតការយកចិត្តទុកដាក់លើនោះឡើយរហូតមកដល់ពេលនេះ។ យើងចាំបាច់ត្រូវធ្វើកិច្ចការបន្ថែមទៀតដើម្បីធានាថា វិមជ្ឈការនៃការផ្តល់សេវានឹងនាំទៅរកអនុវត្តយ៉ាងពិតប្រាកដ ឆ្ពោះទៅរកការលើកកម្ពស់គុណភាពផ្តល់សេវា និងគណនេយ្យភាពដល់ប្រជាពលរដ្ឋ។ ជំហ៊ានដ៏រឹងមាំនានានឹងចាំបាច់ត្រូវធ្វើឡើងដោយរដ្ឋាភិបាលថ្នាក់កណ្តាលឆ្ពោះទៅរកការអនុវត្តពិតប្រាកដនៅថ្នាក់រដ្ឋបាលថ្នាក់ក្រោមជាតិតាមរយៈផែនការការងារ និងថវិកាប្រចាំឆ្នាំ២០១៧ និងឆ្នាំក្រោយៗទៀត។ ដើម្បីឲ្យអាចធ្វើកិច្ចការនេះបាន រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវមានមុខងារដែលត្រូវបានផ្ទេរឲ្យច្បាស់លាស់ជាមួយនឹងអំណាចតាមឋានានុក្រមច្បាស់លាស់ និងមានគណនេយ្យភាព និងធនធានសមស្របដែលអាចផ្តល់សេវាទាំងនោះបាន។ លើសពីនេះ និងជាសារវ័ន្តបំផុតនោះគឺការលើកកម្ពស់ការ**ពិភាក្សាពហុភាគី/ត្រីភាគី**ដែលអ្នកតំណាងមកពីភាគីពាក់ព័ន្ធសំខាន់ៗដូចជា រដ្ឋាភិបាល វិស័យឯកជន និងសង្គមស៊ីវិល ធ្វើកិច្ចការរួមគ្នានៅគ្រប់ដំណាក់កាលអភិវឌ្ឍន៍ទាំងអស់ (រៀបចំផែនការ ការអនុវត្ត និងតាមដាន/វាយតម្លៃ) និងគ្រប់កំរិត។

5. **<u>ហិរញ្ញប្បទាន និងមូលនិធិក្រុង/ស្រុក៖</u>** ដោយមានការគាំទ្រពីមិត្តភក្តិអភិវឌ្ឍន៍របស់យើងក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមកនេះ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ បានបង្កើតមូលដ្ឋានគ្រឹះដ៏រឹងមាំ។ ដូច្នេះវាដល់ពេលហើយសម្រាប់រដ្ឋាភិបាលដើម្បីទទួលខុសត្រូវច្រើនជាងនេះលើការផ្តល់ហិរញ្ញប្បទានដល់កំណែទម្រង់នានា។ ដោយចាប់ផ្តើមពីផែនការការងារ និងថវិកាប្រចាំឆ្នាំ២០១៧ អង្គការសង្គមស៊ីវិល រំពឹងថានឹងមានការបង្កើនច្រើននូវមូលនិធិស្រុក/ក្រុង (DM) លើសមាសធាតុអភិវឌ្ឍន៍ដែលនឹងអាចឲ្យក្រុមប្រឹក្សា និង

រដ្ឋបាលថ្នាក់ក្រោមជាតិ (SNA) ឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋមូលដ្ឋានបាន ខណៈពេលដែលមូលនិធិស្រុក/ក្រុង បច្ចុប្បន្ននៅមានកំរិត។

6. <u>**ការតាមដាន និងវាយតម្លៃ៖**</u> យើងសូមស្នើឲ្យមានការបន្ថែមសមាសធាតុជាអទិភាពមួយបន្ថែមទៀតអំពី "ការពិនិត្យតាមដាន ការវាយតម្លៃ និងការរៀនសូត្រ រួមទាំងការកត់ត្រាការអនុវត្តល្អ" ធ្វើជាអទិភាពសម្រាប់ AWPB ឆ្នាំ២០១៧។

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីជាទីស្នេហា!**

មុននឹងបញ្ចប់សុន្ទរកថារបស់ខ្ញុំ ខ្ញុំសូមបញ្ជាក់ថា អង្គការសង្គមស៊ីវិលប្តេជ្ញាចិត្តនឹងដើរតួនាទីយ៉ាងសំខាន់ក្នុង**ការពិភាក្សាអំពីគោលនយោបាយជាពិសេស ការផ្ទេរនិងការអនុវត្តន៍មុខងារ** ជាមួយរដ្ឋាភិបាលទាំងនៅកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ **ការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស ការពង្រឹងអំណាចដល់ប្រជាពលរដ្ឋ** ឲ្យចូលរួមក្នុងដំណើរការអភិវឌ្ឍន៍ **ការកៀរគរធនធាន** និង**ការបំពេញតួនាទីផ្សេងៗ**ជាច្រើនទៀតសំរាប់គាំទ្រដល់អភិវឌ្ឍន៍ប្រកបដោយប្រជាធិបតេយ្យ និងចិរភាពសំរាប់ប្រទេសកម្ពុជា។

ជាថ្មីម្តងទៀតអង្គការសង្គមស៊ីវិលសូមសម្តែងការកោតសរសើរចំពោះថ្នាក់ដឹកនាំ NCCDS ជាពិសេសឯកឧត្តម **សក់ សេដ្ឋា** និងឯកឧត្តម **ង៉ាន់ ចំរើន** ក្នុងការលើកកម្ពស់ភាពជាដៃគូប្រកបដោយបរិយាប័ន្នក្នុងការអភិវឌ្ឍនិងការអនុវត្តផែនការការងារ និងថវិកាប្រចាំឆ្នាំរហូតមកដល់ពេលនេះ។ យើងមានទំនុកចិត្តយ៉ាងមុតមាំថាតាមរយះវិធីសាស្ត្របែបការចូលរួម និងបរិយាប័ន្នកន្លងមក និងក្នុងអំឡុងពេលពីរថ្ងៃនេះ យើងនឹងបង្កើតផែនការមួយដែលភាគីពាក់ព័ន្ធគ្រប់គ្នា អាចចូលរួមចំណែកធនធានរបស់ខ្លួន មានភាពជាម្ចាស់ខ្លាំងក្លា និងការប្តេជ្ញាចិត្តរយៈពេលវែង ដែលមានសារៈសំខាន់ក្នុងការធ្វើឲ្យកំណែទម្រង់ឲ្យកាន់តែមានប្រសិទ្ធភាព។ យើងសង្ឃឹមថា ជាមួយនឹងវិធីសាស្ត្រនេះ ផែនការការងារ និងថវិកាប្រចាំឆ្នាំ២០១៧ នឹងឆ្លើយតបបានយ៉ាងល្អទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ និងអាជ្ញាធរមូលដ្ឋាន។

ជាថ្មីម្តងទៀត ក្នុងនាមឲ្យអង្គការសង្គមស៊ីវិល សូមអនុញ្ញាតឲ្យខ្ញុំថ្លែងអំណរគុណយ៉ាងកក់ក្តៅដល់ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ដែលអនុញ្ញាតឲ្យយើងចែករំលែកទស្សនៈ ក្តីបារម្ភ និងយោបល់របស់យើងអំពីកំណែទម្រង់ SNDD នៅក្នុងសិក្ខាសាលាដ៏សំខាន់នេះ។ ខ្ញុំសូមជូនពរដល់ឯកឧត្តម អស់លោក លោកស្រី និងប្រជាពលរដ្ឋកម្ពុជាទាំងអស់ឲ្យមានសុខភាពល្អ និងទទួលជោគជ័យក្នុងការងារ និងជីវិតរស់នៅប្រចាំថ្ងៃ។

សូមអរគុណ!